ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Feb-2016, 09:17
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

Translation

## អនុស្សរណៈអន្តរការិយាល័យ

**គោរពជូន:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង
ចៅក្រម គង់ ស្រីម ប្រធានអង្គជំនុំជម្រះតុលាការកំពូល

**ចម្លងជូន:** ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះតុលាការកំពូល
លោក គង់ សំអុន និង អ្នកស្រី Anta GUISSE សហមេធាវីលោក ខៀវ សំផន
លោក Arthur VERCKEN

**ពី:** Isaac Endeley ប្រធានអង្គភាពគាំពារការពារក្តី

កាលបរិច្ឆេទ: ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦

**កម្មវត្ថុ:សេចក្តីសម្រេចទាក់ទងនឹងការដកការចាត់តាំងលោក Arthur VERCKEN ជាសហមេធាវីអន្តរជាតិសម្រាប់លោក ខៀវ សំផន**

---

1. បន្ទាប់ពីអនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៥ និងចម្លើយតបរបស់លោកចៅក្រម ខ្ញុំមានកិត្តិយសជម្រាបលោកចៅក្រមថា អង្គភាពគាំពារការពារក្តីបានសម្រេចជាផ្លូវការដកការចាត់តាំងលោក Arthur VERCKEN ជាសហមេធាវីអន្តរជាតិសម្រាប់លោក ខៀវ សំផន ។

2. ចំណាត់ការនេះធ្វើឡើងបន្ទាប់ពីការឱ្យដំណឹងដោយផ្ទាល់មាត់ និងតាមរយៈសារអេឡិចត្រូនិករបស់លោក Arthur VERCKEN មកអង្គភាពគាំពារការពារក្តីកាលពីថ្ងៃទី១៧, ១៨ និង១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ទាក់ទងនឹងការសម្រេចចិត្តរបស់គាត់ដកខ្លួនចេញពីសំណុំរឿងព្រមទាំងប្រតិកម្មរបស់លោក ខៀវ សំផន នៅថ្ងៃទី២០ និងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ដូចដែលបានពិពណ៌នានៅក្នុងអនុស្សរណៈអន្តរការិយាល័យរបស់ខ្ញុំចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

3. លោក ខៀវ សំផន នឹងត្រូវបន្តការពារនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់នៅចំពោះមុខ អវតក ដោយលោក គង់ សំអុន ជាសហមេធាវីជាតិ និងលោកស្រី Anta GUISSE ជាសហមេធាវីអន្តរជាតិរបស់គាត់ ។

សូមលោកចៅក្រមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ